ÆON NEWS RELEASE

Planting Seeds of Growth
We are ÆON

ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០២២

ក្រុមហ៊ុន អ៊ីអន ម៉ល ខូ អិលធីឌី
ក្រុមហ៊ុន អ៊ីអន ម៉ល (ខេមបូឌា) ខូ អិលធីឌី

# គំនិតផ្តួចផ្តើមថ្មីក្នុងព្រះរាជាណាចក្រកម្ពុជា

« ដើម្បីនាំមកនូវលទ្ធភាពកាន់តែអស្ចារ្យដល់ប្រជាជនកម្ពុជា »

ក្រុមហ៊ុនអ៊ីអនម៉លខូ អិលធីឌី និងក្រុមហ៊ុនអ៊ីអនម៉ល(ខេមបូឌា)ខូ អិលធីឌី មានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែងក្នុងការប្រកាសពីសេចក្តីសម្រេចអភិវឌ្ឍអាជីវកម្មថ្មី ទាក់ទងទៅនឹងមជ្ឈមណ្ឌលដឹកជញ្ជូនពហុមុខងារ ដែលជារចនាសម្ព័ន្ធដឹកជញ្ជូនក្រៅប្រទេសដំបូងគេបង្អស់នៅក្នុងប្រទេសកម្ពុជា។ ការអភិវឌ្ឍអាជីវកម្មថ្មីនេះ ក្រុមហ៊ុនអ៊ីអនម៉ល(ខេមបូឌា)ខូ អិលធីឌី នឹងបង្កើតក្រុមហ៊ុនបុត្រសម្ព័ន្ធ ដែលមានឈ្មោះថា«ក្រុមហ៊ុន អ៊ីអនម៉ល(ខេមបូឌា) ឡូជី ផ្លាស ឯ.ក»។

ជាវិធានការដើម្បីសម្រេចបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព រាជរដ្ឋាភិបាលប្រទេសកម្ពុជា បាននិងកំពុងសិក្សាអំពីគំនិតនៃការធ្វើសមាហរណកម្ម កំពង់ផែក្រុងព្រះសីហនុដែលជាកំពង់ផែមានបរិមាណទំនិញចរាចរច្រើនជាងគេក្នុងស្រុក និងកំពុងមានការអភិវឌ្ឍយ៉ាងឆាប់រហ័ស ជាមួយនឹងផ្នែកមួយដែលមានទីតាំងនៅលើដីគោកនៃតំបន់សេដ្ឋកិច្ចពិសេស ធ្វើជាកំពង់ផែពាណិជ្ជកម្មសេរី ដោយមានការសហការជាមួយរដ្ឋាភិបាលជប៉ុន និងកំពង់ផែស្វយ័តក្រុងព្រះសីហនុ ដែលកំពុងទទួលកិច្ចសហប្រតិបត្តិការបច្ចេកទេសពី ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA)។ ក្រុមហ៊ុនយើង នឹងក្លាយជាក្រុមហ៊ុនសាកល្បងដំបូងគេដែលចូលរួមដើម្បីអោយគំនិតនេះដំណើរការបានជោគជ័យ។ យើងគ្រោងនឹងបើកដំណើរការ មជ្ឈមណ្ឌលដឹកជញ្ជូនពហុមុខងារ ដែលមានអាជ្ញាប័ណ្ណចាំបាច់សម្រាប់ប្រកបអាជីវកម្ម តាមប្រព័ន្ធអេឡិចត្រូនិចឆ្លងដែន ដោយប្រើប្រាស់ភណ្ឌាគារគយមានដែនកំណត់ (Bonded warehouse) នៅក្នុងតំបន់សេដ្ឋកិច្ចពិសេសកំពង់ផែក្រុងព្រះសីហនុ។ មជ្ឈមណ្ឌលនេះមានផ្តល់សេវាកម្មជាកញ្ចប់ក្នុងការគ្រប់គ្រងនិងដឹកជញ្ជូនអីវ៉ាន់ (Fulfillment service) និង សេវាកម្មសម្របសម្រួលនីតិវិធីគយ។

ក្រុមហ៊ុនយើង នឹងដោះស្រាយបញ្ហាដឹកជញ្ជូន ដល់ក្រុមហ៊ុនទាំងអស់ក្នុងប្រទេសកម្ពុជា តាមរយៈការផ្តល់សេវាកម្ម ភណ្ឌាគារគយមានដែនកំណត់ និង សេវាកម្មសម្របសម្រួលនីតិវិធីគយ។ តាមរយៈកិច្ចខិតខំប្រឹងប្រែងទាំងនេះ យើងនឹងបង្កើនភាពងាយស្រួលជូនអតិថិជន ព្រមទាំងផ្តល់ឱកាសអាជីវកម្ម និង សេវាកម្មជាច្រើនប្រភេទ ដល់ក្រុមហ៊ុន ផ្សេងៗ រួមទាំងក្រុមហ៊ុនរបស់យើងផងដែរ។ ក្រុមហ៊ុនយើង នឹងនៅតែបន្តចូលរួមចំណែកក្នុងការអភិវឌ្ឍប្រទេសកម្ពុជាតទៅមុខទៀត។

## ■ ព័ត៌មានទូទៅនៃក្រុមហ៊ុនថ្មី

- ឈ្មោះក្រុមហ៊ុន : អ៊ីអន ម៉ល (ខេមបូឌា) ឡូជី ផ្លាស ឯ.ក
  AEON MALL (CAMBODIA) LOGI PLUS CO., LTD.
- ទីតាំងការិយាល័យ : តំបន់សេដ្ឋកិច្ចពិសេសកំពង់ផែក្រុងព្រះសីហនុ ក្រុងព្រះសីហនុ ប្រទេសកម្ពុជា
- នាយកក្រុមហ៊ុន : Mr. Tsuboya Masayuki
- សកម្មភាពអាជីវកម្ម : ប្រតិបត្តិការ មជ្ឈមណ្ឌលដឹកជញ្ជូន និង ការផ្តល់សេវាផ្សេងៗទៀត

ÆON MALL LOGI PLUS

ÆON MALL

■ **ទិដ្ឋភាពទូទៅនៃមជ្ឈមណ្ឌលដឹកជញ្ជូន**

- ទីតាំងមជ្ឈមណ្ឌល : តំបន់សេដ្ឋកិច្ចពិសេសកំពង់ផែក្រុងព្រះសីហនុ ក្រុងព្រះសីហនុ ប្រទេសកម្ពុជា
- ផ្ទៃដី : ប្រមាណ ៣០,០០០ ម៉ែត្រការ៉េ
- ម្ចាស់អាគារ : អ៊ីអន ម៉ល (ខេមបូឌា) ឡូជី ផ្លាស ឯ.ក
  AEON MALL (CAMBODIA) LOGI PLUS CO., LTD.
- បើកដំណើរការ : ក្នុងឆ្នាំ ២០២៣

